# សិទ្ធិរបស់អ្នក

## ការព្យាបាលការប្រើប្រាស់សារធាតុញៀន

**ក្នុងនាមជាបុគ្គលម្នាក់ដែលរស់នៅក្នុងខោនធី Los Angeles ហើយមានសិទ្ធិទទួលបាន Medi-Cal ឬ កម្មវិធីខោនធីដែលជ្រើសរើសផ្សេងទៀត អ្នកមានសិទ្ធិទទួលបានសេវាព្យាបាលការប្រើប្រាស់សារធាតុញៀនវេជ្ជសាស្ត្រចាំបាច់ដោយមិនគិតថ្លៃសម្រាប់អ្នក។**

## អ្នកក៏មានសិទ្ធិដើម្បីៈ

- ទទួលបានការគោរព និងទទួលបានការថែទាំដោយសេចក្តីថ្លៃថ្នូរ និងគ្មានការរើសអើងចំពោះ ពូជសាសន៍ ដើមកំណើតជាតិ អត្តសញ្ញាណក្រុមជាតិសាសន៍ អាយុ សមត្ថភាពផ្លូវចិត្ត សមត្ថភាពរាងកាយ លក្ខខណ្ឌវេជ្ជសាស្ត្រ សាសនា អត្តសញ្ញាណយេនឌ័រ ឬនិន្នាការផ្លូវភេទរបស់អ្នក។
- ចូលរួមក្នុងការសម្រេចចិត្តអំពីការថែទាំបញ្ហាប្រើប្រាស់សារធាតុញៀនរបស់អ្នក រួមមានសិទ្ធិចំពោះការបដិសេធការព្យាបាល។
- ទទួលបានផែនការផ្តោតសំខាន់លើលទ្ធផលព្យាបាលជាលក្ខណៈបុគ្គល។
- គ្មានការធ្វើបាបផ្លូវចិត្ត និងផ្លូវកាយ ការកេងប្រវ័ញ្ច ការបង្ខិតបង្ខំ និងការចងរាងកាយ។
- ទទួលឯកសារជាលាយលក្ខណ៍អក្សរដែលសំខាន់ចំពោះការថែទាំរបស់អ្នកក្នុងទម្រង់ផ្សេងៗ (ដូចជាភាសាផ្សេងៗ ពុម្ពអក្សរធំ អក្សរស្ទាប និងសំឡេង) តាមការស្នើសុំ។
- ទទួលការព្យាបាលមានការសិក្សាច្បាស់លាស់ និងមានក្រមសីលធម៌ដោយបុគ្គលិកមានសមត្ថភាពក្នុងបរិយាកាសប្រកបដោយសុវត្ថិភាព និងផាសុខភាព។
- ព័ត៌មានសុខភាពរបស់អ្នកត្រូវបានការពារ និងមានភាពសម្ងាត់ និងលទ្ធភាពក្នុងការបដិសេធមិនទទួលបានសាររំអែងាសប្រាក់។
- ទទួលសេវាកម្មក្នុងលក្ខណៈទទួលបានការគោរព និងយល់ដឹងពីឥទ្ធិពលនៃភាសា វប្បធម៌ និងសមត្ថភាពចំពោះបុគ្គលម្នាក់។
- ស្នើសុំ និងទទួលបានច្បាប់ចម្លងនៃកំណត់ត្រាសុខភាពរបស់អ្នក ហើយស្នើសុំឱ្យទិន្នន័យទាំងនេះត្រូវបានកែប្រែ ឬកែតម្រូវ ដូចដែលបានបញ្ជាក់នៅក្នុង 45 CFR §164.524 និង 164.526។
- ទទួលសេវាកម្មបកប្រែផ្ទាល់មាត់ជាភាសាដែលអ្នកពេញចិត្ត។
- ទទួលបានសេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រក្រៅបណ្តាញ ប្រសិនបើខោនធីមិនមានអ្នកផ្តល់សេវាដែលអាចផ្តល់សេវាបាន។
- ទទួលបានការថែទាំទាន់ពេលវេលា។
- ស្នើសុំបណ្តឹងឧទ្ធរណ៍ ប្រសិនបើអ្នកទទួលបានសេចក្តីជូនដំណឹងអំពីការកំណត់អត្ថប្រយោជន៍អវិជ្ជមាន។
- ទទួលបានព្យាបាលក្នុងពេលដំណាលគ្នាសម្រាប់ស្ថានភាពសុខភាពអាកប្បកិរិយាដែលកើតឡើងរួមគ្នា។
- បន្តនៅក្នុងការព្យាបាលដរាបណាអ្នកផ្តល់សេវាព្យាបាលត្រូវបានអនុញ្ញាតឱ្យព្យាបាលអតិថិជន។
- ទទួលបានការគាំទ្រ ការអប់រំ និងការព្យាបាលសម្រាប់គ្រួសារនិងមនុស្សជាទីស្រលាញ់របស់ពួកគេ ប្រសិនបើអ្នកផ្តល់ការព្យាបាលត្រូវបានអនុញ្ញាតឱ្យផ្តល់សេវាទាំងនេះ។
- ធ្វើការតវ៉ាទៅកាន់មណ្ឌលព្យាបាលដែលអ្នកទទួលការថែទាំរបស់អ្នកនិងខោនធី និងក្នុងករណីមួយចំនួន លេខាធិការផ្នែកសេវាសុខភាព និងមនុស្ស និងទទួលបានការឆ្លើយតប។
- ប្រប្រាស់សិទ្ធិទាំងនេះដោយមិនរងផងប៉ះពាល់អវិជ្ជមានដល់សេវាកម្មដែលអ្នកទទួលបាន។

សម្រាប់ព័ត៌មានបន្ថែមចំពោះសិទ្ធិរបស់អ្នក សូមមើល សៀវភៅណែនាំអ្នកជំងឺ របស់អ្នក ឬចូលទៅកាន់ publichealth.lacounty.gov/sapc/PatientPublic.htm សម្រាប់សិទ្ធិផ្សេងទៀតទាំងអស់ ដូចដែលបានចែងដោយច្បាប់ ឬបទប្បញ្ញត្តិ។



SAPC Substance Abuse Prevention and Control

County of Los Angeles Public Health